**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**មន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍ខេត្តស្ទឹងត្រែង**

**ក្រុមលទ្ធកម្ម**

លេខ : ...០១០.......លកបទ.សត

# សេចក្តីជូនដំណឹង

## ស្តីពី

## ការអញ្ជើញចូលរួមដេញថ្លៃ ជួសជុលរបង ក្លោងទ្វារខាងមុខមន្ទីរប្រវែង៧០ម៉ែត្រ របងចំហៀង និងខាងក្រោយប្រវែង ៤៥ម៉ែត្រ ជូនមន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍ ខេត្តស្ទឹងត្រែង សម្រាប់ឆ្នាំ២០១៦

មន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍ សូមជូនដំណឹងដល់បណ្តាក្រុមហ៊ុន/សហគ្រាស (គិតទាំងសហគ្រាសឯកត្តបុគ្គល) ទាំងអស់ ដែលបានចុះបញ្ជីត្រឹមត្រូវក្នុងព្រះរាជាណាចក្រកម្ពុជាអោយបានជ្រាបថា មន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍ខេត្តស្ទឹងត្រែង នឹងដាក់ឱ្យដេញថ្លៃ ជាសាធារណៈដើម្បីជ្រើសរើសអ្នកទទួលការធ្វើការងារជួសជុល **របង ក្លោងទ្វារ ខាងមុខមន្ទីរប្រវែង ៧០ម៉ែត្រ (របងខាងមុខកម្ពស់ ២ម៉ែត្រ៣តឹក និងក្លោងទ្វារកម្ពស់ ៣ម៉ែត្រ ៨តឹក) របងចំហៀង និងខាងក្រោយប្រវែង ៤៥ម៉ែត្រ កម្ពស់ ២ម៉ែត្រ សម្រាប់ឆ្នាំ២០១៦ ។**

មន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍ បានរៀបចំឯកសារសម្រាប់ក្រុមហ៊ុន/សហគ្រាសបំពេញដើម្បីចូលរួមដេញថ្លៃ និងមានដាក់លក់នៅមន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍ ដែលមានអាសយដ្ឋានភូមិព្រែក សង្កាត់ស្ទឹងត្រែង ក្រុងស្ទឹងត្រែង ខេត្តស្ទឹងត្រែង ចាប់ពីថ្ងៃទី ០៦...... ខែ តុលា......ឆ្នាំ ២០១៦ តទៅ រៀងរាល់ម៉ោងធ្វើការ (ទូរស័ព្ទទាក់ទងលេខ ០៩៧ ៩៨០ ១៣ ៨៨) ។

កាលបរិច្ឆេទឈប់ទទួលសំណើដេញថ្លៃ នៅម៉ោង១៤ម៉ោង០០.. ថ្ងៃទី០៨.... ខែវិច្ឆិកា.......ឆ្នាំ២០១៦។

ការបើកសំណើដេញថ្លៃ នឹងប្រព្រឹត្តទៅនៅមន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍ តាមអាសយដ្ឋានខាងលើ វេលាម៉ោង១៤ម៉ោង០០... ថ្ងៃទី ០៨......... ខែ វិច្ឆិកា.......... ឆ្នាំ២០១៦ ។

ក្រុមហ៊ុន/សហគ្រាសដែលមានសម្ព័ន្ធភាពជាមួយគ្នា ឬមានប្រភពតែមួយ អាចដាក់សំណើដេញថ្លៃបានតែមួយគត់ ។

ក្រុមហ៊ុន/សហគ្រាសដែលមានបំណងចូលរួមដេញថ្លៃ សូមអញ្ជើញទាក់ទងជាមួយក្រុមលទ្ធកម្មមន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍ខេត្តស្ទឹងត្រែង ដើម្បីទិញឯកសារដេញថ្លៃ និងសាកសួរព័ត៌មាន ដែលទាក់ទងនឹងការដេញថ្លៃនេះ ។

ធ្វើនៅស្ទឹងត្រែង ថ្ងៃទី ...២២... ខែសីហា.. ឆ្នាំ២០១៦

**ប្រធានក្រុមលទ្ធកម្មមន្ទីរប្រៃសណីយ៍**

**និងទូរគមនាគមន៍ ខេត្តស្ទឹងត្រែង**

**នេត ច័ន្ទខរិន្ទ**

**ចម្លងជូន ៖**

-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ)

-អង្គភាពប្រឆាំងអំពើពុករលួយ

-ឯកសារ-កាលប្បវត្តិ